កិច្ចការ១៨:៩-១៩:៧

**[៩]វេលាយប់នោះ ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅប៉ុលក្នុងការជាក់ស្តែងថា កុំខ្លាចអ្វី ចូរសំដែងទៅ កុំនៅស្ងៀមឡើយ [១០]ដ្បិតខ្ញុំនៅជាមួយនឹងអ្នកហើយ គ្មានអ្នកណានឹងប្រទូស្តដល់អ្នកបានទេ ខ្ញុំក៏មានមនុស្សជាច្រើននៅក្នុងទីក្រុងនេះដែរ (កិច្ចការ១៨:៩-១០)។**

ព្រះអម្ចាស់សន្យាដល់សាវ័កប៉ុលថា "...ខ្ញុំក៏មានមនុស្សជាច្រើននៅក្នុងទីក្រុងនេះដែរ"។ ហេតុអ្វីបានជាចាំបាច់ព្រះអម្ចាស់សន្យាដល់សាវ័កប៉ុល នូវព្រះបន្ទូលនេះ? ទីក្រុងកូរិនថូស គឺជាសំបុកមនុស្សអាក្រក់គ្រប់បែបយ៉ាង គឺសំបុកចោរ សំបុកស្រីពេស្យាចារ សំបុកល្បែងស៊ីសង និងជាសំបុកការអាក្រក់ផ្សេងៗទៀត។ បើព្រះអម្ចាស់មិនធានាអះអាងថាទីនោះមានកូនព្រះអង្គជាច្រើនដែរនោះទេ សាវ័កប៉ុលច្បាស់ជាមិននៅទីនោះយូរឡើយ។ ព្រះជាម្ចាស់មានផែនការសម្រាប់មនុស្សមានបាប ពោលគឺព្រះអង្គចង់អោយមនុស្សមានបាបស្គាល់ពន្លឺរបស់ទ្រង់។ នៅក្នុងទីក្រុងដែលគ្របបាំងដោយអំពើបាបគ្រប់បែបយ៉ាង ព្រះអង្គចង់អោយសាវ័កប៉ុលជ្រាបថា ទ្រង់មានពន្លឺជាច្រើនចាំចែងនៅទីនោះ។ ពន្លឺរបស់ទ្រង់ស្ថិតនៅក្នុងពួកអ្នកជឿរៀងរាល់រូប។ ដូច្នេះបានជាព្រះជាម្ចាស់សន្យាដល់សាវ័កប៉ុលថា ទោះបីទីក្រុងនេះមានអំពើអាក្រក់ជា

ច្រើនយ៉ាងណាក៏ដោយ ទ្រង់អះអាងប្រាប់សាវកប៉ុលថា "...ខ្ញុំក៏មានមនុស្សជាច្រើននៅក្នុងទីក្រុងនេះដែរ"។

**គាត់ក៏នៅទីនោះអស់១ឆ្នាំ៦ខែ ព្រមទាំងបង្រៀនព្រះបន្ទូលនៅក្នុងពួកគេ (កិច្ចការ១៨:១១)។**

ក្រោយពេលដែលសាវ័កប៉ុលស្នាក់នៅទីនោះចំនួនដប់ប្រាំបីខែ ការប្រឆាំងនឹងដំណឹងល្អក៏ចាប់ផ្ដើមឡើង។

**កាលលោកកាលីយ៉ូធ្វើជាអ្នកដំណាងសាសន៍រ៉ូម នៅស្រុកអាខៃ នោះពួកសាសន៍យូដាលើកគ្នា ព្រួតទាស់នឹងប៉ុល គេចាប់នាំគាត់ទៅឯទីជំនុំក្តី ចោទថា (កិច្ចការ១៨:១២)។**

គេចាប់សាវ័កប៉ុលទៅឯទីជំនុំក្តី។ នៅទីនោះហើយដែលសាវ័កប៉ុលអាចនិយាយសេចក្ដីជាច្រើនដូចបានកត់ទុកនៅក្នុងសំបុត្ររបស់លោក ផ្ញើទៅពួកជំនុំនៅទីក្រុងកូរិនថូស។ សាវ័កប៉ុលមានប្រសាសន៍ទៅកាន់ពួកអ្នកក្រុងកូរិនថូសពីទីជំនុជំរះក្តីនៅពេលដែលគេនាំគ្នាយកលោកទៅចោទប្រកាន់ពីការផ្សាយដំណឹងល្អ។

**អ្នកនេះជាអ្នកបញ្ចុះបញ្ចូលមនុស្ស ឱ្យថ្វាយបង្គំព្រះខុសច្បាប់ (កិច្ចការ១៨:១៣)។**

ពាក្យថា "ខុសច្បាប់" មិនមែនមានន័យថា សាវ័កប៉ុលអធិប្បាយព្រះបន្ទូលខុសនឹងច្បាប់រាជការរ៉ូម ឬខុសច្បាប់អាជ្ញាធរនៅក្នុងទីក្រុងកូរិនថូសទេ។ ពាក្យថា "ខុសច្បាប់" គឺជាការខុសច្បាប់ នឹងក្រឹត្យវិន័យរបស់លោកម៉ូសេ។

**[១៤]"តែកាលប៉ុលរៀបនឹងបើកមាត់ដោះសាខ្លួន នោះលោកកាលីយ៉ូនិយាយទៅពួកសាសន៍យូដាថា នែ ពួកសាសន៍យូដាអើយ បើសិនណាជាមានការទុច្ចរិតណា ឬទោសកំណាចអ្វីដទៃ នោះតាមទំនងខ្ញុំត្រូវតែទទួលស្តាប់អ្នករាល់គ្នា [១៥]ប៉ុន្តែ បើសិនជាកើតក្តីពីដំណើរពាក្យសំដី ឬពីនាមឈ្មោះ ឬពីក្រិត្យវិន័យរបស់អ្នករាល់គ្នាវិញ នោះស្រេចនឹងអ្នករាល់គ្នាចុះ ខ្ញុំមិនចូលចិត្តនឹងជំនុំជំរះចំពោះការយ៉ាងនោះទេ [១៦]លោកក៏បណ្តេញគេចេញពីសាលាជំនុំជំរះទៅ [១៧]នោះគេក៏ចាប់សូស្ថេន ជាមេសាលាប្រជុំ មកវាយផ្ចាលនៅមុខសាលាជំនុំ តែលោកកាលីយ៉ូមិនរវល់សោះ (កិច្ចការ ១៨:១៤-១៧)។**

កន្លងមកមានអ្នកបកស្រាយគម្ពីរខ្លះ ថ្កោលទោសដល់កិរិយាប្រព្រឹត្តរបស់លោកកាលីយ៉ូដែលជាមន្ត្រីមួយរូបរបស់រាជការរ៉ូម គ្រប់គ្រងអំណាចនៅស្រុកអាខៃ។ គេចោទប្រកាន់ថា មន្ត្រីក្រសួងយុត្តិធម៌នាមកាលីយ៉ូជាមនុស្ស គ្មានមនោសញ្ចេតនាចំពោះមនុស្សលោកនៅក្នុងសម័យនោះ។ ប៉ុន្តែបើយើងសង្កេតអោយបានល្អិតល្អន់ លោកកាលីយ៉ូ គឺជាមន្ត្រីមួយរូបដែលស្គាល់នាទីរបស់លោកច្បាស់លាស់ជាទីបំផុត។ លោកកាលីយ៉ូមិនបានជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទេ។ លោកជាចៅក្រមប្រចាំតំបន់អាខៃ។ លោកមាននាទីតែម្យ៉ាងគត់ គឺធ្វើអោយប្រព័ន្ធយុត្តិធម៌របស់សាសន៍រ៉ូមមានតម្លាភាពក្នុងការកាត់ក្តីដល់ប្រជាពលរដ្ឋ។ លោកកាលីយ៉ូប្រកាន់ឥរិយាបថថា រឿងសាសនា ត្រូវដោះស្រាយតាមច្បាប់សាសនា រឿងច្បាប់រដ្ឋ ត្រូវដោះស្រាយតាមក្រសួងយុត្តិធម៌។ លោកជាមន្ត្រីជាន់ខ្ពស់មួយរូប ដែលប្រកាន់ថាសាសនានិងរដ្ឋ ត្រូវមាននយោបាយដាច់ពីគ្នា។ រឿងទាក់ទងជាមួយសាសនា អ្នកមានជំនាញខាងសាសនាត្រូវដោះស្រាយខ្លួនឯង។ រឿងណាទាក់ទងនឹងការរំលោភច្បាប់រដ្ឋ ភ្នាក់ងាររាជការដែលមានជំនាញ ត្រូវដោះស្រាយតាមច្បាប់របស់នគរ។ លោកមិនចង់អោយមានរឿងជំពាក់ជំពិនជាមួយនឹងរឿងសាសនា ព្រោះលោកមិនមានជំនាញក្នុងទំនៀមទម្លាប់សាសនា របស់សាសនាយូដាទេ។ នៅពេលសាវ័កប៉ុលអធិប្បាយព្រះបន្ទូលរបស់ព្រះអង្គនៅទីក្រុងកូរិនថូស លោកមិនលូកដៃទៅរំខានឡើយ។ ក្រុងកូរិនថូសមាន

សេរីភាពគ្រប់បែបយ៉ាង រួមទាំងសេរីភាពការអនុវត្តន៍សាសនានិងជំនឿផង។

យើងចង់ឃើញក្រសួងយុត្តិធម៌នៅក្នុងសង្គមរបស់យើង មាននយោបាយរដ្ឋដាច់ដោយឡែកពីសាសនា។ ក្រសួងយុត្តិធម៌ត្រូវដោះស្រាយបញ្ហាការរំលោភច្បាប់នានារបស់នគរ។ អ្នកមានជំនាញខាងសាសនា ត្រូវដោះស្រាយបញ្ហាគោលទ្ធិ នឹងការអនុវត្តន៍សាសនា ដែលរដ្ឋធម្មនុញ្ញទទួលស្គាល់។ បើអ្នកកាន់សាសនាធ្វើអ្វីខុសនឹងច្បាប់របស់រដ្ឋ គេត្រូវកាត់ទោសបុគ្គលរូបនោះ តាមច្បាប់របស់នគរ។ រឿងនេះទាក់ទងនឹងការអនុវត្តន៍សាលនា ក្នុងស្ថាប័នរដ្ឋជាតួយ៉ាង ការអធិស្ឋានក្នុងសាសារៀនសាធារណៈ។ ភ្នាក់ងាររាជការមិនត្រូវបង្ខិតបង្ខំសិស្សសាលា អោយអធិស្ឋាននៅក្នុងសាលាសាធារណៈឡើយ។ បើឪពុកម្តាយភាគច្រើន ដែលមានសិស្សចូលរៀននៅសាលាណាមួយ សម្រេចចិត្តថា ត្រូវមានការអធិស្ឋាននៅក្នុងសាលារបស់ខ្លួន សាសានោះត្រូវធ្វើការនោះចុះ។ ប៉ុន្តែរាជការមិនត្រូវបង្ខិតបង្ខំអោយសិស្សត្រូវធ្វើការអធិស្ឋានមុនចូលរៀនទេ។ បើរដ្ឋធម្មនុញ្ញប្រទេសយើងគាំទ្រអោយមានសេរីភាពក្នុងការនិយាយស្តី និងសេរីភាពក្នុងការប្រកាន់យកសាសនាណាមួយ តាមចំណង់ចំណូលចិត្តរបស់ពលរដ្ឋ។ ច្បាប់រដ្ឋត្រូវពង្រឹងដោយភ្នាក់ងាររាជការ ដែលទទួលនាទីខាងពង្រឹងច្បាប់រដ្ឋ។ ច្បាប់សាសនាត្រូវប្រគល់នាទីអោយអ្នកមានជំនាញខាងសាសនា ជាអ្នកដោះស្រាយរឿងសាសនាដោយខ្លួនចុះ។ ច្បាប់សាសនាត្រូវមានលក្ខណៈឯករាជ្យ ពីច្បាប់របស់រដ្ឋ។ ប៉ុន្តែ កាលណាអ្នកកាន់សាសនារំលោភច្បាប់របស់រដ្ឋ ភ្នាក់ងាររាជការមានសិទ្ធិកាត់ទោសដល់បុគ្គល ដែលរំលោភច្បាប់រដ្ឋក្នុងនាមសាសនា។ មន្ត្រីជាន់ខ្ពស់ នាមកាលីយ៉ូ

គឺជាមន្ត្រីមួយរូបដែលណែនាំអោយយើងចេះប្រើច្បាប់សាសនា ដាច់ដោយឡែកពីច្បាប់របស់រដ្ឋ។

## សាវ័កប៉ុលចុះសំពៅត្រឡប់មកក្រុងអាន់ទីយ៉ូកវិញ

**ឯប៉ុល គាត់នៅទីនោះជាយូរថ្ងៃទៀត រួចក្រោយដែលគាត់បានកោរសក់នៅក្រុងកេងគ្រាហើយ គឺដោយព្រោះគាត់បានបន់បំណន់ នោះក៏លាពួកជំនុំ ចុះសំពៅទៅឯស្រុកស៊ីរីវិញ មានទាំងព្រីស៊ីល នឹងអ័គីឡា ទៅជាមួយផង (កិច្ចការ១៨:១៨)។**

ហេតុអ្វីបានជាសាវ័កប៉ុល ធ្វើការបែរបន់? ពេលលោកនៅក្រោមគ្រាព្រះគុណហើយ អ្នកខ្លះនិយាយថា សាវ័កប៉ុលដែលជាគ្រូអធិប្បាយក្រោមគ្រាព្រះគុណមិនគួរធ្វើការបែរបន់អ្វីទេ។ អ្នកដែលបន្ទោសសាវ័កប៉ុលក្នុងករណីនេះ ធ្វើច្បាប់ចង្អៀតចង្អល់អោយលោកខ្លាំងពេកណាស់។ សាវ័កប៉ុលមានសិទ្ធិគ្រប់បែបយ៉ាង ក្នុងគ្រាដែលលោកស្ថិតនៅក្រោមគ្រាព្រះគុណ។ បើលោកចង់ធ្វើការបែរបន់ណាមួយ នោះជាសិទ្ធិរបស់លោក។ ឯយើងក៏ដូចគ្នាដែរ ពេលស្ថិតនៅក្រោមគ្រាព្រះគុណ យើងអាចធ្វើការបែរបន់អ្វីមួយនៅចំពោះព្រះ ស្រេចនៅលើសិទ្ធិសេរីភាពរបស់យើង។ ប៉ុន្តែសាវ័កប៉ុលបង្ហាត់បង្រៀនដល់មនុស្សដទៃទៀតថា មិនគួរធ្វើការបែរបន់អ្វីទេ បើមិន

មានសុជន្ទៈនឹងធ្វើតាមការបែរបន់នោះអោយសម្រេចឡើយ។ ប៉ុន្តែខ្លួនលោក បើលោកចង់ធ្វើការបែរបន់ ជាសិទ្ធិរបស់លោក។ យើងមានសេរីភាពគ្រប់គ្រាន់ក្នុងពេលដែលយើងរស់នៅក្រោមគ្រាព្រះគុណ។

រឿងនេះទាក់ទងនឹងគ្រីស្ទបរិស័ទខ្លះ ដែលធ្វើច្បាប់ផ្សេងៗសម្រាប់អនុវត្តក្នុងក្រុមរបស់ខ្លួន។ អ្នកខ្លះរិះគន់ថា គ្រីស្ទបរិស័ទមិនចាំបាច់ធ្វើច្បាប់នានាបន្ថែមពីលើច្បាប់ដែលមាននៅក្នុងព្រះគម្ពីរឡើយ។ ខ្ញុំយល់ថា បើគ្រីស្ទបរិស័ទក្រុមណា ចង់ធ្វើច្បាប់បែបនោះ ជាសេរីភាពរបស់ក្រុមខ្លួន។ ប៉ុន្តែក្រុមនោះមិនអាចបង្គាប់បញ្ជាអោយគ្រីស្ទបរិទ័សដទៃទៀត ធ្វើតាមច្បាប់របស់ក្រុមខ្លួនជាដាច់ខាត។

ឧទាហរណ៍ បើក្រុមណាមួយចង់ទទួលទានសាច់ ក្រុមនោះមានសេរីភាពគ្រប់គ្រាន់និងទទួលទានបាន។ បើក្រុមណាជ្រើសរើសថ្ងៃណាមួយ ដើម្បីថ្វាយបង្គំដល់ព្រះជាម្ចាស់ រឿងនោះជាសិទ្ធិរបស់ក្រុមគេ។ សាវ័កប៉ុលរំឭកដល់ពួកជំនុំនៅទីក្រុងកូរិនថូសថា "ដូច្នេះ ទោះបើស៊ីឬផឹក ឬធ្វើការអ្វីក៏ដោយ នោះចូរធ្វើទាំងអស់សំរាប់ចំរើនសិរីល្អដល់ព្រះចុះ" (១កូរិនថូស១០:៣១)។ សេចក្ដីដែលសំខាន់ជាគេបង្អស់ជុំវិញការដែលយើងធ្វើអ្វីមួយ ត្រូវសួរថា តើទង្វើរបស់យើង មនុស្សដទៃលើក ឬបង្គាប់សិរីល្អរបស់ព្រះ? បើបរិភោគសាច់ជាការចម្រើនសិរីល្អដល់ព្រះជាម្ចាស់ សូមទទួលទានដោយសេរីចុះ។ ឯអ្នកណាដែលតមសាច់ ក៏គេចង់រកសិរីល្អ ដើម្បីចម្រើនដល់ព្រះជាម្ចាស់ដែរ។

យើងមិនត្រូវចាប់កំហុសសាវ័កប៉ុល ក៏ដូចជាមិនត្រូវចាប់កំហុសដល់មន្ត្រីជាន់

ខ្ពស់របស់សាសន៍រ៉ូមមួយរូបនាមលោកកាលីយ៉ូដែរ។ ខគម្ពីរដែលយើងកំពុងសិក្សានេះ ហាក់ដូចជាងាយសម្រាប់គេរកកំហុសដល់សាវ័កប៉ុល និងលោកកាលីយ៉ូ។ យើងមិនត្រូវយកខគម្ពីរទាំងនេះទៅចាប់កំហុសលោកទេ។

ឥឡូវ សាវ័កប៉ុលធ្វើដំណើរត្រឡប់មកពីការបំពេញបេសកកម្មលើកទីពីររបស់លោកហើយ។ លោកត្រូវធ្វើដំណើរត្រឡប់ទៅទីក្រុងអាន់ទីយ៉ូកខេត្តស៊ីរី ដែលជាក្រុមជំនុំរបស់លោកវិញ។ លោកចុះសំពៅនៅក្រុងកេគ្រា។ សាវ័កប៉ុលធ្វើដំណើរត្រឡប់មកពីការបំពេញបេសកកម្មលើកទីពីរ ដោយនាំយកលោកអ័គីឡា និងព្រីស៊ីល្លាមកជាមួយផង។ លោកមិនធ្វើដំណើរទៅខាងលិចទៀតទេ គឺលោកត្រូវចុះសំពៅត្រឡប់មកផ្ទះវិញ។

**កាលទៅដល់ក្រុងអេភេសូរហើយ នោះប៉ុលទុកគេនៅទីនោះ តែគាត់ចូលទៅក្នុងសាលាប្រជុំរបស់សាសន៍យូដា ហើយក៏ជជែកពន្យល់ដល់គេ (កិច្ចការ១៨:១៩)។**

សូមកុំភ្លេច ពេលដែលសាវ័កប៉ុលចេញដំណើរបេសកកម្មលើកទីពីរ ព្រះវិញ្ញាណរបស់ព្រះមិនអនុញ្ញាត អោយលោកចូលទៅផ្សាយដំណឹងល្អនៅទីក្រុងអេភេសូរទេ។ នៅពេលនេះទើបព្រះជាម្ចាស់អនុញ្ញាតអោយលោកសំចតនៅទីក្រុងអេភេសូរ ក្នុងរយៈពេលយ៉ាងខ្លី។

**២០ រួចគេសូមឱ្យគាត់នៅជាមួយនឹងគេជាយូរបន្តិចទៀត តែគាត់**
**មិនព្រមទេ ២១ គាត់លាគេទៅដោយពាក្យថា ខ្ញុំត្រូវតែទៅធ្វើបុណ្យ**
**ក្រោយនេះ នៅក្រុងយេរូសាឡិមជាមិនខាន តែបើព្រះទ្រង់សព្វ**
**ព្រះហឫទ័យ នោះខ្ញុំនឹងត្រឡប់មកឯអ្នករាល់គ្នាវិញ រួចគាត់ចុះ**
**សំពៅ ចេញពីអេភេសូរទៅ (កិច្ចការ១៨:២០-២១)។**

សាវ័កប៉ុលចង់ទៅចូលរួមពិធីបុណ្យថ្ងៃទី៥០ ដែលគេត្រូវធ្វើនៅទីក្រុងយេរូ-សាឡិម។ លោកមានសិទ្ធិគ្រប់បែបយ៉ាងនឹងចូលរួមពិធីបុណ្យណា តាមតែលោកមានចិត្តចង់ធ្វើ។ លោកស៊ីម៉ូន-ពេត្រុស និងសាវ័កប៉ុលមានគំនិតដូចគ្នា ពោលគឺលោកនៅជាប់ជំពាក់ជាមួយនឹងបុណ្យខ្លះៗ ដែលក្រឹត្យវិន័យរបស់លោកម៉ូសេតម្រូវអោយលោកធ្វើ។ នៅក្នុងពិធីបុណ្យ ទីក្រុងយេរូសាឡិមមានមិត្តសម្លាញ់របស់សាវ័កប៉ុលច្រើននាក់ ដែលមកចូលរួមទីនោះ។ លោកមានចិត្តជាបេសកជន បានជាលោកចេះតែចង់ទៅជួបមិត្តភក្តិរបស់លោក ដើម្បីប្រាប់អំពីដំណឹងល្អនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

ចិត្តរបស់លោក ម្យ៉ាងចង់ទៅទីក្រុងយេរូសាឡិម ដើម្បីចូលរួមពិធីបុណ្យរបស់សាសន៍យូដា ម្យ៉ាងចង់នៅទីក្រុងអេភេសូរ ពីព្រោះលោកឃើញមានទ្វារបើកសម្រាប់ការផ្សព្វផ្សាយរបស់ដំណឹងល្អហើយ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ លោកត្រូវត្រឡប់ទៅទីក្រុងយេរូសាឡិមសិន។ លុះចប់ពិធីបុណ្យ លោកនឹងត្រឡប់មកផ្សាយដំណឹងល្អនៅទីក្រុងអេភេសូរនេះទៀត។ ទីក្រុងអេភេសូរ គឺជាទីក្រុងដ៏ធំមួយនៅក្នុង

ចក្រភពរ៉ូម។

**លុះចូលចតនៅក្រុងសេសារាហើយ ក៏ឡើងទៅជំរាបសួរដល់ពួកជំនុំ រួចចុះទៅឯអាន់ទីយ៉ូកវិញ (កិច្ចការ១៨:២២)។**

លោកចុះសំពៅនៅទីក្រុងសេសារា។ ផែទីក្រុងសេសារា និងទីក្រុងយ៉ុបប៉េ គឺជាផែដែលមានសំពៅចុះឡើងទីក្រុងយេរូសាឡិម។ លោកចុះសំពៅធ្វើដំណើរទៅកាន់ទីក្រុងយេរូសាឡិម រួចហើយធ្វើដំណើរ ផ្លូវគោកទៅជើង សំដៅទៅវិហាររបស់លោកនៅទីក្រុងអាន់ទីយ៉ូកវិញ។ ពេលនេះជាពេលដែលលោកបញ្ចប់ដំណើរបេសកកម្មលើកទីពីររបស់លោកហើយ។

មិនយូរប៉ុន្មាន លោកនឹងចាប់ផ្តើមដំណើរបេសកកម្មលើកទីបីរបស់លោកថែមទៀត។

**គាត់នៅទីនោះជាយូរព្រែល រួចចេញទៅដើរកាត់ស្រុកកាឡាទី នឹងស្រុកព្រីគាដោយលំដាប់ ព្រមទាំងតាំងឱ្យពួកសិស្សទាំងអស់បានខ្ជាប់ខ្ជួនឡើង (កិច្ចការ១៨:២៣)។**

ចាប់ផ្តើមពីខនេះទៅ សាវ័កប៉ុលធ្វើដំណើរបេសកកម្មលើកទីបី។ ក្នុងការ

ធ្វើដំណើរបេសកកម្មលើកទីបី លោកត្រូវធ្វើដំណើរកាត់ស្រុកកាឡាទីម្តងទៀត។ នៅពេលចាប់ផ្តើមធ្វើដំណើរបេសកកម្មលើកទីបី លោកចូលទៅទីក្រុងអេភេសូរតែម្តង។ កិច្ចការរបស់សាវ៉កប៉ុលនៅទីក្រុងអេភេសូរបានរីកចម្រើនខ្លាំងណាស់។ ប៉ុន្តែ មុននឹងលោកទៅដល់មានមនុស្សម្នាក់អធិប្បាយយ៉ាងខ្លាំងក្លា នៅក្នុងទីក្រុងនោះរួចហើយ។ អ្នកអធិប្បាយរូបនោះ នាមលោកអ័ប៉ុឡូស។ លោកអ័ប៉ុឡូសមិន មែនជាគ្រូអធិប្បាយល្បីល្បាញដូចសាវ៉កប៉ុលទេ តែយើងអាចស្គាល់លោកបានច្បាស់ក្នុងពេលបន្តិចទៀត។

## កិច្ចការលោកអ័ប៉ុឡូសនៅក្រុងអេភេសូរ

**នៅក្នុងគ្រានោះ មានសាសន៍យូដាម្នាក់ ឈ្មោះអ័ប៉ុឡូស ដែលកើតនៅក្រុងអ័លេក្សានទ្រា ជាអ្នកមានវោហារ ហើយក៏ចេះស្ទាត់ក្នុងគម្ពីរដែរ គាត់មកដល់ក្រុងអេភេសូរ (កិច្ចការ១៨:២៤)។**

លោកអ័ប៉ុឡូសជាសាសន៍យូដា តែមានឈ្មោះជាសាសន៍ក្រេក។ ក្នុងនាមលោកជាសាសន៍យូដា លោកចេះស្ទាត់នូវក្រឹត្យវិន័យរបស់លោកម៉ូសេ។ លោកកើតនៅទីក្រុងអាលេក្សានទ្រា គឺជាទីក្រុងធំមួយនៅទ្វីបអាហ្វ្រិកខាងជើង។ ទីក្រុងនេះគឺជាមជ្ឈមណ្ឌលវប្បធម៌របស់សាសន៍ក្រេក ដែលមានសកលវិទ្យាល័យធំៗជាច្រើន មានបណ្ណាល័យ ដែលធំជាងគេបង្អស់នៅក្នុងសកលលោកទាំងមូល។ នៅក្នុងទីក្រុង

នេះហើយ ដែលគេបកស្រាយគម្ពីរសញ្ញាចាស់មកជាភាសាក្រេក។ គម្ពីរនោះគេហៅថាជាគម្ពីរសិពទូអឹហ្សិនទ៍។ ក្រុងអាលេក្សានទ្រា មានសាលាប្រជុំរបស់សាសន៍យូដាជាច្រើនដែរ។ នៅក្នុងសម័យដើម ទំនាក់ទំនងរវាងទីក្រុងអាលេក្សានទ្រា ក្រុងយេរូសាឡិម ហើយនិងក្រុងអាន់ទីយ៉ូកមានការជិតស្និទ្ធគ្នាជាខ្លាំងណាស់។ មនុស្សបីរូប ដែលសុទ្ធតែជាអ្នកមានឥទ្ធិពលលើក្រុមជំនុំសម័យដើម រស់នៅក្នុងទីក្រុងអាលេក្សានទ្រា។ លោកទាំងបីរូបនោះមានទាម អាថាណោសៀស ធំរធូលីយាន និងលោកអ័ប្បើស្ទីន។ អ្នកប្រាជ្ញមួយរូបទៀតនាមហ្វីឡូ គឺជាអ្នកដែលយកលាយវប្បធម៌សាសន៍ក្រេក មកលាយជាមួយនឹងវប្បធម៌សាសន៍យូដា។ អ្នកប្រាជ្ញរូបនេះព្យាយាមលាយទស្សនៈរបស់លោកប្លាតូ ជាមួយនឹងសាសនាយូដា។ លោកអ័ប៉ុឡូសទទួលឥទ្ធិពលយ៉ាងខ្លាំង អំពីទស្សនៈវិជ្ជានេះ។

ម្យ៉ាងវិញទៀតយើងឃើញថា លោកអ័ប៉ុឡូសជាអ្នកមានវោហារ ព្រមទាំងជាអ្នកចេះគម្ពីរយ៉ាងស្ទាត់ជំនាញផង។

> **គាត់បានសិក្សាខាងឯផ្លូវព្រះអម្ចាស់ ហើយដោយព្រោះគាត់មានចិត្តឧស្សាហ៍ បានជាគាត់អធិប្បាយ ហើយបង្រៀនយ៉ាងត្រឹមត្រូវពីអស់ទាំងសេចក្តីខាងឯព្រះអម្ចាស់ ទោះបើស្គាល់តែបុណ្យជ្រមុជរបស់លោកយ៉ូហានក៏ដោយ (កិច្ចការ១៨:២៥)។**

"គាត់បានសិក្សាខាងឯផ្លូវព្រះអម្ចាស់..." មានន័យថា គេបង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះដល់គាត់ ដោយមាត់ទទេតែប៉ុណ្ណោះ ពោលគឺមិនមានជាការបើកសម្ដែងអ្វីទេ។ គាត់មានចិត្តឧស្សាហ៍ មិនមែនដោយសារព្រះវិញ្ញាណបរិសុទ្ធដឹកនាំលោកទេ ពីព្រោះលោកមិនទាន់បានស្គាល់ព្រះអម្ចាស់យេស៊ូវទេ។ លោកអ័ប៉ុឡូសចេះអធិប្បាយ ហើយបង្រៀនយ៉ាងត្រឹមត្រូវ តាមការជ្រមុជទឹករបស់លោកយ៉ូហាន។ លោកមិនទាន់បានឮពីព្រះនាមរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅឡើយ។

**ហើយគាត់ចាប់តាំងអធិប្បាយក្នុងសាលាប្រជុំ ដោយក្លាហាន កាលអ័គីឡា នឹងព្រីស៊ីល បានឮ នោះក៏នាំទៅពន្យល់ពីផ្លូវព្រះឲ្យរឹតតែច្បាស់នៅទៀត (កិច្ចការ១៨:២៦)។**

នៅពេលដែលលោកអ័គីឡា និងព្រីស៊ីលឃើញលោកអ័ប៉ុឡូសអធិប្បាយត្រឹមការជ្រមុជទឹករបស់យ៉ូហាន លោកទាំងពីរក៏ណែនាំ អោយលោកអ័ប៉ុឡូសស្គាល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាអង្គសង្គ្រោះរបស់លោក។

**រួចគាត់គិតនឹងទៅឯស្រុកអាខៃ នោះពួកជំនុំក៏ធ្វើសំបុត្រផ្ញើទៅទូន្មានពួកសិស្សឲ្យទទួលគាត់ លុះដល់ហើយ គាត់ក៏ជួយយ៉ាងសន្ធឹក ដល់ពួកអ្នកដែលជឿដោយព្រះគុណ (កិច្ចការ១៨:២៧)។**

លោកអ័ប៉ុឡូស គឺជាមនុស្សឆ្លាតវាងវៃណាស់ តែលោកមិនទាន់បានស្គាល់ព្រះគុណរបស់ព្រះជាម្ចាស់នៅឡើយ ទាល់តែលោកអ័គីឡានិងព្រីស៊ីលនាំលោកអោយស្គាល់អំពីសេចក្តីសង្គ្រោះដោយសារព្រះគុណ។

**ព្រោះគាត់ជជែកផ្ចាញ់ពួកសាសន៍យូដា នៅកណ្តាលជំនុំ ដោយប៉ិនប្រសប់ ទាំងបង្ហាញតាមគម្ពីរថា ព្រះយេស៊ូវជាព្រះគ្រីស្ទមែន (កិច្ចការ១៨:២៨)។**

ក្រោយពីលោកបានជឿដល់ព្រះអម្ចាស់យេស៊ូវហើយ លោកអាចជជែកផ្ចាញ់ពួកសាសន៍យូដាយ៉ាងប៉ិនប្រសព្វ ព្រមទាំងបង្ហាញនៅក្នុងគម្ពីរថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ។ បន្ទាប់ពីពេលនោះមក លោកក៏ចុះទៅស្រុកអាខៃ ដើម្បីពង្រឹងក្រុមជំនុំនៅក្នុងស្រុកក្រេក នៅក្នុងក្រុងកូរិនថូស និងក្រុងអាថែន។ ទីណាដែលលោកទៅដល់ លោកតែងតែអធិប្បាយថា ព្រះយេស៊ូវគ្រីស្ទគឺជាអង្គសង្គ្រោះដែលសាសន៍យូដានិងមនុស្សដទៃទៀតរង់ចាំជាយូរមកហើយ។

# ជំពូក ១៩

*ទាវចនា ដំណើរបេសកកម្មលើកទីបីរបស់សាវ័កប៉ុល*

ដំណើរបេសកកម្មលើកទីបីរបស់សាវ័កប៉ុល ចាមផ្ដើមនៅក្នុងជំពូក១៨:២៣ ពោលគឺពេលដែលលោកចាកចេញពីទីក្រុងអាន់ទីយ៉ូក ខេត្តស៊ីរី។ ជំពូក១៩ រ៉ាយរ៉ាប់អំពីដំណើរបេសកកម្មរបស់លោកលើកទីមួយនឹងលើកទីពីរ និងដំណើរដែលសាវ័កប៉ុលមកដល់ទីក្រុងអេភេសូរ។ លោកបង្ហាត់បង្រៀនរៀងរាល់ថ្ងៃ នៅទីក្រុងនោះ អស់រយៈពេលពីរឆ្នាំ។ សេចក្ដីបង្រៀននិងទីសម្គាល់ដែលសាវ័កប៉ុលបានធ្វើ ញុំាងអោយ ដេមេទ្រាសជាជាងទង នាំគ្នាធ្វើបាតុកម្មបះបោរទាស់ជាមួយនឹងគាត់។ រឿងនោះ ធ្វើអោយអាជ្ញាធរនៅក្នុងទីក្រុងបង្ក្រាបបាតុកម្ម ក្រែងលោការបះបោរបែបនេះ បែរទៅជាខុសច្បាប់រាជការរ៉ូមដោយប្រការណាមួយ។

## កិច្ចការសាវ័កប៉ុលនិងក្រុងអេភេសូរ

**[១] កំពុងដែលអ័ប៉ុឡូសនៅក្រុងកូរិនថូស នោះប៉ុលបានដើរកាត់អស់ទាំងស្រុកខាងលើ រហូតដល់ក្រុងអេភេសូរ កាលគាត់រកឃើញ**

**សិស្សខ្លះ នោះក៏សួរថា ²ចាប់តាំងពីអ្នករាល់គ្នាជឿមក តើបានទទួលព្រះវិញ្ញាណបរិសុទ្ធហើយឬនៅ គេឆ្លើយថា យើងខ្ញុំមិនបានទាំងឮនិយាយពីព្រះវិញ្ញាណបរិសុទ្ធផង (កិច្ចការ១៩:១-២)។**

នៅពេលជិតបញ្ចប់ដំណើរបេសកកម្មលើកទីពីរ សាវ័កប៉ុលឈប់សំចតអស់រយៈពេលខ្លីនៅទីក្រុងអេភេសូរ ដើម្បីធ្វើការផ្សព្វផ្សាយព្រះបន្ទូល។ លោកសន្យាដល់អ្នកនៅទីក្រុងអេភេសូរថា បើព្រះសព្វព្រះហឫទ័យ លោកនឹងត្រឡប់មកទីក្រុងនេះវិញ។ ឥឡូវ លោកបានត្រឡប់មកទីក្រុងនេះមែន។ ប៉ុន្តែ មុននឹងលោកមកដល់ មានគ្រូអធិប្បាយយ៉ាងចំណានមួយរូប គឺលោកអ័ប៉ុឡូស បានត្រៀមចិត្តមនុស្សនៅទីក្រុងនោះរួចទៅហើយ។ លោកអ័ប៉ុឡូសបានអធិប្បាយយ៉ាងខ្លាំងក្លានៅក្នុងទីក្រុងអេភេសូរ ប៉ុន្តែភាគច្រើនលោកមិនបានអធិប្បាយអំពីសេចក្តីសុគតនិងការរស់ឡើងវិញរបស់ព្រះអម្ចាស់យេស៊ូវទេ។ ពីលោកអ័គីឡា និងព្រីស៊ីលបានណែនាំលោកអោយស្គាល់ព្រះអម្ចាស់យេស៊ូវ។ ការអធិប្បាយរបស់លោកអ័ប៉ុឡូសបាននាំមនុស្សជាច្រើនអោយជឿនិងទទួលបុណ្យជ្រមុជទឹកក្នុងនាមលោកយ៉ូហានដែរ។ ដូច្នេះ បានជាសាវ័កប៉ុលសួរដល់អ្នកដែលបានជ្រមុជទឹករួចហើយថា "ចាប់តាំងពីអ្នករាល់គ្នាជឿមក តើបានទទួលព្រះវិញ្ញាណបរិសុទ្ធហើយឬនៅ..."។ អ្នកស្រុកឆ្លើយថា "...យើងខ្ញុំមិនបានទាំងឮនិយាយពីព្រះវិញ្ញាណបរិសុទ្ធផង"។ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គមិនទាន់យាងមកគង់ ជាមួយនឹងអ្នកទទួលបុណ្យជ្រមុជទឹកនៅទីក្រុងអេភេសូរ ពីព្រោះគេមិនទាន់

ជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅឡើយ។

**គាត់សួរគេទៀតថា ដូច្នេះ តើអ្នករាល់គ្នាបានទទួលបុណ្យជ្រមុជទឹកដោយនូវអ្វី គេឆ្លើយថា គឺដោយនូវបុណ្យជ្រមុជរបស់លោកយ៉ូហានទេ (កិច្ចការ១៩:៣)។**

ខខាងលើបញ្ជាក់ថា ការជ្រមុជទឹកដោយទឹក មិនអាចជួយអោយមនុស្សរួចពីបាបទេ។ អ្នកស្រុកទាំងនោះមិនទាន់ទទួលព្រះវិញ្ញាណបរិសុទ្ធ ពីព្រោះគេមិនទាន់បានទទួលសេចក្តីសង្គ្រោះនៅឡើយ។ ប៉ុន្តែនៅក្នុងវិនាទីដែលបុគ្គលម្នាក់ជឿទុកចិត្តលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ព្រះវិញ្ញាណបរិសុទ្ធបានបំផ្លាស់ជននោះ អោយទៅជាអ្នកកើតជាថ្មី។ ចាប់ពីពេលនោះទៅ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គយាងមកគង់ប្រថាប់នៅក្នុងជីវិតរបស់បុគ្គលនោះ ព្រមទាំងបោះត្រានៃព្រះវិញ្ញាណនៅលើចិត្តរបស់អ្នកនោះថែមទៀតផង។ បុគ្គលនោះត្រូវទទួលការជ្រមុជដោយព្រះវិញ្ញាណ ដើម្បីបញ្ចូលទៅក្នុងរូបកាយរបស់ពួកអ្នកជឿ។ ហេតុការណ៍ទាំងអម្បាលមាណនេះ កើតឡើងនៅពេលដែលលោកអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សាវ័កប៉ុលសង្កេតឃើញថា មនុស្សដែលបានទទួលបុណ្យជ្រមុជទឹកក្នុងនាមលោកយ៉ូហាន មិនទាន់បានជឿដល់ព្រះអម្ចាស់យេស៊ូវទេ។ ដូច្នេះ បានជាសាវ័កប៉ុលបង្ហាត់បង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ ដើម្បីអោយគេបានរួចពីបាប។ មនុស្សនៅទីក្រុងអេភេសូរជាច្រើនបានជឿ

ដល់ដំណឹងល្អ ដែលសាវ័កប៉ុលបានអធិប្បាយ។

> **៤ រួចប៉ុលនិយាយថា លោកយ៉ូហានបានធ្វើបុណ្យជ្រមុជទឹក ពី**
> **ដំណើរការប្រែចិត្ត ទាំងប្រាប់ពួកជនឱ្យជឿដល់ព្រះអង្គ ដែល**
> **យាងមកក្រោយលោកវិញ គឺដល់ព្រះយេស៊ូវគ្រីស្ទ**
> **៥ កាលបានឮ ដូច្នោះហើយ នោះគេក៏ទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាម**
> **ព្រះអម្ចាស់យេស៊ូវវិញ (កិច្ចការ១៩:៤-៥)។**

បន្ទាប់ពីសាវ័កប៉ុលផ្សាយដំណឹងល្អថា អ្នកដែលជឿដល់ព្រះអម្ចាស់យេស៊ូវបានរួចពីបាប មនុស្សជាច្រើនបានទទួលជឿដល់ព្រះអម្ចាស់យេស៊ូវ។ នៅពេលនោះព្រះវិញ្ញាណបរិសុទ្ធក៏យាងមកសណ្ឋិតនៅលើគេ។

អត្ថបទខាងលើ មានអ្នកបកស្រាយគម្ពីរខ្លះប្រកាន់ថា នៅទីក្រុងអេភេសូរ មានអ្នកទទួលព្រះអម្ចាស់យេស៊ូវរួចហើយ ប៉ុន្តែ មិនទាន់បានទទួលព្រះវិញ្ញាណបរិសុទ្ធនៅឡើយ ទាល់តែសាវ័កប៉ុលអញ្ជើញទៅដាក់ដៃនៅលើគេ។ ការបង្ហាត់បង្រៀនបែបនេះ មិនត្រឹមត្រូវទេ ពីព្រោះព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គមិនសណ្ឋិតនៅលើពួកអ្នកជ្រមុជទឹកនៅទីក្រុងអេភេសូរ ពីព្រោះអ្នកទាំងនោះ មិនទាន់បានទទួលសេចក្តីសង្គ្រោះក្នុងនាមព្រះអម្ចាស់យេស៊ូវនៅឡើយ។

**៦រួចប៉ុលដាក់ដៃលើគេ ហើយព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើគេ នោះគេចាប់តាំងនិយាយភាសាដទៃ ហើយអធិប្បាយផង ៧ពួកអ្នកទាំងនោះមានគ្នាប្រហែលជា១២នាក់ (កិច្ចការ១៩:៦-៧)។**

បន្ទាប់ពីព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតនៅលើអ្នកជឿ នៅទីក្រុងអេភេសូរហើយ គេចេះនិយាយភាសាដទៃ។ ឯភាសាដទៃនោះទៀតសោត គឺគេស្តាប់បានតាមភាសារបស់គេរៀងខ្លួន។ ទីក្រុងអេភេសូរជាទីក្រុងធំ ដែលមានមនុស្សច្រើនសាសន៍អាស្រ័យនៅ។ ដូច្នេះ ពេលដែលព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតនៅលើគេ គេក៏ចេះនិយាយភាសាដទៃដែលគេអាចស្តាប់បាន។ ហេតុការណ៍នេះកើតឡើងនៅក្នុងក្រុងយេរូសាឡិមនៅថ្ងៃទីហាសិបដែរ។

ក្នុងពេលនេះ សាវ័កប៉ុលបានចាប់ផ្តើមកិច្ចការរបស់លោកនៅទីក្រុងអេភេសូរហើយ។ រវាងទីក្រុងកូរិនថូស និងទីក្រុងអេភេសូរ សាវ័កប៉ុលបំពេញកិច្ចការបានរីកចម្រើនច្រើនជាង នៅក្នុងទីក្រុងអេភេសូរ។

យើងស្វែះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"